**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៤៥០ សហវ.ប្រក.

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រម នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងអាជ្ញាប័ណ្ណស្វែងរុករក និងអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ១៩៥ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.រក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្ដីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសារាចរណែនាំលេខ០៧ សរណន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាល ស្ដីពីវិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលសិលា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

ការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ត្រូវបានរៀបចំជាបញ្ជីផាកពិន័យដែលមានរាយលម្អិតអំពីប្រភេទបទល្មើស និងកម្រិតទឹកប្រាក់ពិន័យទៅតាមប្រភេទបទល្មើសនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ។

ឧបសម្ព័ន្ធទី១ : ជាបញ្ជីផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងរ៉ែ និងថាមពល។

ឧបសម្ព័ន្ធទី២ : ជាបញ្ជីផាកពិន័យ ដែលក្រសួងរ៉ែ និងថាមពលធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ២ .–**

ការផាកពិន័យលើប្រភេទបទល្មើសនីមួយៗ ត្រូវអនុវត្តតាមនីតិវិធីដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល។

**ប្រការ៣ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងរ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ រតនៈ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
  ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ.៤៩០..... សហវ.ប្រក.អទច ចុះថ្ងៃទី.២៤. ខែ.កក្កដា ឆ្នាំ២០២៤ ស្តីពីការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល

## បញ្ជីផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងរ៉ែ និងថាមពល

| លេខរៀងបទល្មើស | បរិយាយប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| | I- **វិស័យរ៉ែ** | |
| ១ | ១ បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែដោយគ្មានអាជ្ញាបណ្ណធនធានរ៉ែ<br>(កថាខណ្ឌទី១ មាត្រា៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ពី ៥០០ ០០០<br>ដល់ ១ ០០០ ០០០ |
| ២ | ២ បុគ្គលណាដែលធ្វើប្រតិបត្តិការស្វែងរុករកល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា៧ ឬមាត្រា៨ នៃច្បាប់នេះ<br>(កថាខណ្ឌទី១ នៃមាត្រា៣៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ពី ៥ ០០០ ០០០<br>ដល់ ១០ ០០០ ០០០ |
| ៣ | ៣ បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយគ្មានអាជ្ញាបណ្ណធនធានរ៉ែ ឬល្មើសនឹងមាត្រា៧ ឬមាត្រា៨ នៃច្បាប់នេះ<br>(កថាខណ្ឌទី១ នៃមាត្រា៣៥ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ១ ៥០០ ០០០ ក្នុងមួយថ្ងៃ ឬស្មើនឹង២ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែដែលជីកយកបាន ដោយជ្រើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង |
| ៤ | ៤ បុគ្គលណាដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាបណ្ណធនធានរ៉ែអស់សុពលភាព ឬក្រៅដែនអាជ្ញាបណ្ណ ឬមិនបានដាក់ពាក្យស្នើសុំពន្យារបន្តអាជ្ញាបណ្ណធនធានរ៉ែទាន់ពេលវេលា<br>(កថាខណ្ឌទី១ មាត្រា៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ១ ៥០០ ០០០ ក្នុងមួយថ្ងៃ ឬស្មើនឹង២ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែដែលជីកយកបាន ដោយជ្រើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង |

| លេខរៀងបទល្មើស | | បរិយាយប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| ៥ | ៥ | សម្បទានិកដែលមិនគោរពតាមលក្ខខណ្ឌដូចមានបញ្ញត្តិក្នុងអាជ្ញាបណ្ណធនធានរ៉ែ<br>(កថាខណ្ឌទី២ នៃមាត្រា៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ពី ៥ ០០០ ០០០<br>ដល់ ៥០ ០០០ ០០០ |
| ៦ | ៦ | បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា៣០ថ្មី នៃច្បាប់នេះ (ដឹកជញ្ជូនធនធានរ៉ែ ឬផលិតផលរ៉ែចេញពីការដ្ឋាន ដោយមិនទាន់បានបង់សួយសារ ឬគ្មានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ)<br>(កថាខណ្ឌទី១ មាត្រា៣៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ស្មើនឹង២ដង នៃតម្លៃធនធានរ៉ែ ឬផលិតផលរ៉ែដែលបានដឹកចេញពីការដ្ឋាន |
| ៧ | ៧ | សម្បទានិកដែលមិនអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចធនធានរ៉ែចុះត្រួតពិនិត្យដូចមានចែងក្នុងមាត្រា២៣ថ្មី នៃច្បាប់នេះ<br>(មាត្រា៣៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ពី ៥ ០០០ ០០០<br>ដល់ ១០ ០០០ ០០០ |
| | II- **វិស័យប្រេងកាត** | | |
| ៨ | ១ | នីតិបុគ្គលដែលធ្វើសកម្មភាពស្វែងរុករក អភិវឌ្ឍ ឬផលិតកម្មប្រេងកាតដោយគ្មានកិច្ចព្រមព្រៀងប្រេងកាត ឬកិច្ចព្រមព្រៀងប្រេងកាតត្រូវបានព្យួរ<br>(កថាខណ្ឌទី២ មាត្រា៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ) | ពី ៤ ០០០ ០០០ ០០០<br>ដល់ ៤០ ០០០ ០០០ ០០០ |
| ៩ | ២ | រូបវន្តបុគ្គលណាដែលធ្វើសកម្មភាពបុរេសនាក្នុងផ្ទៃកអាប់ស្រ្ទីមដោយគ្មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល<br>(កថាខណ្ឌទី១ មាត្រា៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ១០ ០០០ ០០០<br>ដល់ ៥០ ០០០ ០០០ |
| ១០ | ៣ | នីតិបុគ្គលដែលធ្វើសកម្មភាពបុរេសនាក្នុងផ្ទៃកអាប់ស្រ្ទីមដោយគ្មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល<br>(កថាខណ្ឌទី៣ មាត្រា៥៩ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ១០០ ០០០ ០០០<br>ដល់ ១ ០០០ ០០០ ០០០ |
| ១១ | ៤ | អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតដែលមិនបំពេញកាតព្វកិច្ចដូចមានចែងក្នុងចំណុច ក ឬខ នៃមាត្រា២០ នៃច្បាប់នេះ (ប្រសិទ្ធភាពតាមលក្ខណៈបច្ចេកទេស ឧត្តមានុវត្ត និងបទដ្ឋានអន្តរជាតិ ហើយធ្វើឱ្យខូចខាតដល់បរិស្ថានដោយការធ្វេសប្រហែស ឬដោយចេតនា)<br>(កថាខណ្ឌទី១ មាត្រា៦០ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ៤០០ ០០០ ០០០<br>ដល់ ២ ០០០ ០០០ ០០០ |

| លេខរៀងបទល្មើស | បរិយាយប្រភេទបទល្មើស | | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| ១២ | ៥ | ក្នុងករណីនៅតែប្រព្រឹត្តអំពើល្មើសម្តងទៀត ទៅនឹងចំណុចទី៤ ខាងលើនេះ<br>(កថាខណ្ឌទី២ មាត្រា៦០ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ៨០០ ០០០ ០០០<br>ដល់ ៤ ០០០ ០០០ ០០០ |
| ១៣ | ៦ | អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតដែលមិនបំពេញកាតព្វកិច្ចដូចមានចែងក្នុងចំណុចគ ឬចំណុច ឃ នៃមាត្រា២០ នៃច្បាប់នេះ (ការការពារសុខភាព និងសុវត្ថិភាពការងារហើយនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ ឬបណ្តាលឱ្យអ្នកដទៃស្លាប់ដោយការធ្វេសប្រហែស ឬដោយចេតនា)<br>(កថាខណ្ឌទី១ មាត្រា៦១ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ៤០០ ០០០ ០០០<br>ដល់ ២ ០០០ ០០០ ០០០ |
| ១៤ | ៧ | ក្នុងករណីនៅតែប្រព្រឹត្តអំពើល្មើសម្តងទៀត ទៅនឹងចំណុច៦ ខាងលើនេះ<br>(កថាខណ្ឌទី២ មាត្រា៦១ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ៨០០ ០០០ ០០០<br>ដល់ ៤ ០០០ ០០០ ០០០ |
| ១៥ | ៨ | អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតដែលយឺតយ៉ាវមិនបានផ្តល់ទិន្នន័យប្រេងកាត ព័ត៌មាន និងរបាយការណ៍បច្ចេកទេសណាមួយ ឬទាំងអស់ ពីប្រតិបត្តិការប្រេងកាតជូនក្រសួងរ៉ែ និងថាមពល តាមពេលវេលាកំណត់ដូចមានចែងក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬក្រោយពីទទួលបានការកំណត់ជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ក្នុងអំឡុងពេលយ៉ាងយូរ ៩០ (កៅសិប)ថ្ងៃ<br>(កថាខណ្ឌទី១ មាត្រា៦៣ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ៥០ ០០០ ០០០<br>ដល់ ១ ០០០ ០០០ ០០០ |
| ១៦ | ៩ | បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយគ្មានអាជ្ញាបណ្ណស្របតាមកថាខណ្ឌទី១ នៃមាត្រា៤១ នៃច្បាប់នេះ<br>(កថាខណ្ឌទី១ មាត្រា៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ១ ០០០ ០០០ រៀល<br>ដល់ ១០០ ០០០ ០០០ |
| ១៧ | ១០ | បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយគ្មានលិខិតអនុញ្ញាតស្របតាមកថាខណ្ឌទី១ នៃមាត្រា៤១ នៃច្បាប់នេះ<br>(កថាខណ្ឌទី២ មាត្រា៦៤ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ២០០ ០០០<br>ដល់ ១០ ០០០ ០០០ |
| ១៨ | ១១ | បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយពុំគោរពតាមបទប្បញ្ញត្តិបច្ចេកទេសដែលចេញដោយក្រសួងរ៉ែ និងថាមពល ស្របតាមមាត្រា៤៨ នៃច្បាប់នេះ<br>(មាត្រា៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ពី ១ ០០០ ០០០<br>ដល់ ៥០ ០០០ ០០០ |

| លេខរៀងបទល្មើស | | បរិយាយប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| ១៩ | ១២ | បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយគ្មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព ឬផុតសុពលភាព ហើយមិនបានដាក់ពាក្យស្នើសុំបន្តពីក្រសួងរ៉ែ និងថាមពល ដូចមានចែងក្នុងមាត្រា៤២ នៃច្បាប់ និងមាត្រា៨នៃអនុក្រឹត្យ មុននឹងចាប់ផ្ដើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបម្រើសកម្មភាពផ្នែកដោនស្ទ្រីម ដែលហេដ្ឋារចនាសម្ព័ន្ធនោះមានតម្លៃក្រោម ៨០០ ០០០ ០០០ (ប្រាំបីរយលាន) រៀល (ចំណុចក នៃកថាខណ្ឌទី១ មាត្រា៦៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) (កថាខណ្ឌទី១ មាត្រា៣៧ នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ៤ ០០០ ០០០ |
| ២០ | ១៣ | ក្នុងករណីនៅតែប្រព្រឹត្តអំពើល្មើសម្ដងទៀត ទៅនឹងចំណុច១២ ខាងលើនេះ (កថាខណ្ឌទី២ មាត្រា៦៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ៨ ០០០ ០០០ |
| ២១ | ១៤ | បុគ្គលណាដែលធ្វើសកម្មភាពផ្នែកដោនស្ទ្រីមដោយគ្មានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព ឬផុតសុពលភាពហើយមិនបានដាក់ពាក្យស្នើសុំបន្ត ពីក្រសួងរ៉ែ និងថាមពល ដូចមានចែងក្នុងមាត្រា៤២ នៃច្បាប់ និងមាត្រា៨នៃអនុក្រឹត្យ មុននឹងចាប់ផ្ដើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបម្រើសកម្មភាពផ្នែកដោនស្ទ្រីម ដែលហេដ្ឋារចនាសម្ព័ន្ធនោះមានតម្លៃចាប់ពី ៨០០ ០០០ ០០០ (ប្រាំបីរយលាន) រៀល (ចំណុចខ នៃកថាខណ្ឌទី១ មាត្រា៦៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) (កថាខណ្ឌទី១ មាត្រា៣៧ នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ១០ ០០០ ០០០ |
| ២២ | ១៥ | ក្នុងករណីនៅតែប្រព្រឹត្តអំពើល្មើសម្ដងទៀត ទៅនឹងចំណុច១៤ ខាងលើនេះ (កថាខណ្ឌទី២ មាត្រា៦៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត) | ២០ ០០០ ០០០ |
| ២៣ | ១៦ | ក្នុងករណីដែលក្រសួងរ៉ែ និងថាមពលតម្រូវឱ្យមានការរុះរើហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្ទ្រីម ឬមធ្យោបាយដឹកជញ្ជូន ហើយបុគ្គលនោះ មិនព្រមធ្វើការរុះរើ (គិតក្នុងមួយថ្ងៃ) (កថាខណ្ឌទី២ មាត្រា៣៧ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម ) | ពី ១ ០០០ ០០០ ដល់ ៥ ០០០ ០០០ |

| លេខរៀង<br>បទល្មើស | បរិយាយប្រភេទបទល្មើស | កម្រិតទឹកប្រាក់<br>ដែលត្រូវពិន័យ<br>(រៀល) |
|---|---|---|
| ២៤ | ១៧ បុគ្គលណាដែលមិនអនុលោមតាមលក្ខខណ្ឌកំណត់នៅក្នុងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព<br>(កថាខណ្ឌទី១ មាត្រា៣៨ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ២០០ ០០០<br>ដល់ ១០ ០០០ ០០០ |
| ២៥ | ១៨ បុគ្គលណាដែលមិនអនុលោមតាមលក្ខខណ្ឌកំណត់នៅក្នុងអាជ្ញាបណ្ណ<br>(កថាខណ្ឌទី២ មាត្រា៣៨ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ១ ០០០ ០០០<br>ដល់ ២០ ០០០ ០០០ |
| ២៦ | ១៩ បុគ្គលណាដែលមិនអនុលោមតាមលក្ខខណ្ឌកំណត់នៅក្នុងលិខិតអនុញ្ញាត<br>(កថាខណ្ឌទី៣ មាត្រា៣៨ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ២០០ ០០០<br>ដល់ ៥ ០០០ ០០០ |
| ២៧ | ២០ បុគ្គលណាដែលធ្វើសកម្មភាពពាក់ព័ន្ធផ្នែកដោនស្ទ្រីមដោយពុំមានលិខិតអនុញ្ញាតពីក្រសួងរ៉ែ និងថាមពល (គិតក្នុងមួយករណី)<br>(កថាខណ្ឌទី១ មាត្រា៣៩ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ១ ០០០ ០០០<br>ដល់ ១០ ០០០ ០០០ |
| ២៨ | ២១ ក្នុងករណីនៅតែប្រព្រឹត្តអំពើល្មើសម្តងទៀត ទៅនឹងចំណុចទី២០ ខាងលើនេះ (គិតក្នុងមួយករណី)<br>(កថាខណ្ឌទី២ មាត្រា៣៩ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ២ ០០០ ០០០<br>ដល់ ២០ ០០០ ០០០ |
| ២៩ | ២២ បុគ្គលណាដែលមិនរក្សាសុពលភាពនៃបណ្ណសន្យារ៉ាប់រងក្នុងអំឡុងពេលសុពលភាពនៃលិខិតអនុញ្ញាត (គិតក្នុងមួយថ្ងៃ)<br>(កថាខណ្ឌទី១ មាត្រា៤០ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ១០០ ០០០<br>ដល់ ៥០០ ០០០ |
| ៣០ | ២៣ បុគ្គលណាដែលមិនរក្សាសុពលភាពនៃបណ្ណសន្យារ៉ាប់រងក្នុងអំឡុងពេលសុពលភាពនៃអាជ្ញាបណ្ណ ដូចមានចែងក្នុងមាត្រា២៦ នៃអនុក្រឹត្យនេះ ដែលធ្វើសកម្មភាពដោយគ្មានសុពលភាព នៃបណ្ណសន្យារ៉ាប់រង (គិតក្នុងមួយថ្ងៃ)<br>(កថាខណ្ឌទី២ មាត្រា៤០ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ៥០០ ០០០<br>ដល់ ១ ០០០ ០០០ |
| ៣១ | ២៤ រូបវន្តបុគ្គលណាដែលមិនរក្សាទុកទិន្នន័យនិងកំណត់ត្រា<br>(ត្រទី១ មាត្រា៤១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ១ ០០០ ០០០<br>ដល់ ៥ ០០០ ០០០ |

| លេខរៀងបទល្មើស | | បរិយាយប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| ៣២ | ២៥ | នីតិបុគ្គលណាដែលមិនរក្សាទុកទិន្នន័យ និងកំណត់ត្រា<br>(ត្រេទី២ មាត្រា៤១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ៥ ០០០ ០០០<br>ដល់ ១០ ០០០ ០០០ |
| ៣៣ | ២៦ | រូបវន្តបុគ្គលណាដែលមិនផ្តល់របាយការណ៍តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល<br>(ត្រេទី១ មាត្រា៤២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ១ ០០០ ០០០<br>ដល់ ៥ ០០០ ០០០ |
| ៣៤ | ២៧ | នីតិបុគ្គលណាដែលមិនផ្តល់របាយការណ៍តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល<br>(ត្រេទី២ មាត្រា៤២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម) | ពី ៥ ០០០ ០០០<br>ដល់ ១០ ០០០ ០០០ |
| | III- **វិស័យថាមពល** | | |
| | ក. លិខិតអនុញ្ញាតនាំចូល និងប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម | | |
| ៣៥ | ១ | បុគ្គលណាធ្វើការនាំចូលសារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី១ និងទី២ នៃឯកសារ IAEA<br>No.RS-G-1.9 - 2005 ដោយគ្មានលិខិតអនុញ្ញាតនាំចូល (គិតក្នុងមួយប្រភព) | ៤ ០០០ ០០០ |
| ៣៦ | ២ | បុគ្គលណាធ្វើការនាំចូលសារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី៣ ដល់ទី៥ នៃឯកសារ IAEA<br>No.RS-G-1.9 - 2005 ដោយគ្មានលិខិតអនុញ្ញាតនាំចូល (គិតក្នុងមួយប្រភព) | ២ ៥០០ ០០០ |
| ៣៧ | ៣ | បុគ្គលណាប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី១ និងទី២ នៃឯកសារ IAEA<br>No.RS-G-1.9 - 2005 ដោយគ្មានលិខិតអនុញ្ញាតប្រើប្រាស់ (គិតក្នុងមួយប្រភព) | ៤ ០០០ ០០០ |
| ៣៨ | ៤ | បុគ្គលណាប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី៣ ដល់ទី៥ នៃឯកសារ IAEA<br>No.RS-G-1.9 - 2005 ដោយគ្មានលិខិតអនុញ្ញាតប្រើប្រាស់ (គិតក្នុងមួយប្រភព) | ៣ ០០០ ០០០ |
| ៣៩ | ៥ | នីតិបុគ្គលណាដែលប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី១ និងទី២ នៃឯកសារ IAEA<br>No.RS-G-1.9 - 2005 ដោយផុតសុពលភាពលិខិតអនុញ្ញាតប្រើប្រាស់ (គិតក្នុងមួយប្រភព) | ៣ ០០០ ០០០ |

| លេខរៀងបទល្មើស | បរិយាយប្រភេទបទល្មើស | | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| ៤០ | ៦ | នីតិបុគ្គលណាដែលប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម នៅក្នុងចំណាត់ថ្នាក់ទី៣ ដល់ទី៥ នៃឯកសារ IAEA No.RS-G-1.9 - 2005 ដោយផុតសុពលភាពលិខិតអនុញ្ញាតប្រើប្រាស់ (គិតក្នុងមួយប្រភព) | ២ 000 000 |
| ៤១ | ៧ | នីតិបុគ្គលណាដែលបានទទួលលិខិតអនុញ្ញាតប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម ពីក្រសួងរ៉ែ និងថាមពល ហើយខកខានក្នុងការបញ្ជូនរបាយការណ៍វិភាគលទ្ធផលតាមដានកម្រិតវិទ្យុសកម្មសម្រាប់បុគ្គលិកមកក្រសួងរ៉ែ និងថាមពល តាមការកំណត់ (គិតក្នុងមួយថ្ងៃ) | ១0 000 |
| ៤២ | ៨ | នីតិបុគ្គលណា ដែលបានទទួលលិខិតអនុញ្ញាតនាំចូលនិងប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ហើយមិនអនុវត្ត ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពស្របតាមលក្ខខណ្ឌតម្រូវ លក្ខណៈបច្ចេកទេស ឧត្តមានុវត្ត និង/ ឬបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងសុវត្ថិភាពវិទ្យុសកម្ម និងសន្តិសុខវិទ្យុសកម្មនៃការប្រើប្រាស់ | ពី ១00 000 ទៅ ៥ 000 000 |
| | **ខ. ការអនុញ្ញាតវិនិយោគសម្រាប់ប្រព័ន្ធនិងកិច្ចប្រតិបត្តិការ ផលិតនិងចែកចាយថាមពលចំហាយ (សម្រាប់ការវិនិយោគឯកជន)** | | |
| ៤៣ | ៩ | នីតិបុគ្គលណា ដែលធ្វើការផលិត ចែកចាយ ឬ ផ្តល់សេវាកម្មថាមពលចំហាយ ដោយគ្មានលិខិតអនុញ្ញាតនិង/ ឬអាជ្ញាបណ្ណ (គិតក្នុងមួយថ្ងៃ) | ពី ៤00 000 ទៅ ៤ 000 000 |
| ៤៤ | ១0 | អ្នកកាន់អាជ្ញាបណ្ណធ្វើសេវាកម្មថាមពលចំហាយណា ដែលប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ ឬ បទប្បញ្ញត្តិផ្តល់សេវាកម្មថាមពលចំហាយ (គិតក្នុងមួយថ្ងៃ) | ពី ៤00 000 ទៅ ៤ 000 000 |
| ៤៥ | IV- **ការដាក់ពិន័យក្នុងករណីបង់ប្រាក់យឺតយ៉ាវឬហួសកាលបរិច្ឆេទតម្រូវឱ្យបង់ប្រាក់** (គិតក្នុងមួយខែ តាមរូបមន្តសមាស) | | ២%នៃទឹកប្រាក់ត្រូវបង់ |

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ៤៩០..... សហវ.ប្រក.អទច ចុះថ្ងៃទី២៤. ខែកក្កដា. ឆ្នាំ២០២៤ ស្តីពីការផាកពិន័យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល

**បញ្ជីផាកពិន័យ ដែលក្រសួងរ៉ែ និងថាមពលធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត**

| លេខរៀងបទល្មើស | បរិយាយប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| | **I- វិស័យរ៉ែ** | |
| ១ | ១ សម្បទានិកដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ អស់សុពលភាព សម្រាប់អាជីវកម្មជីកយកអាចម៍ដី ដីក្រហម ខ្សាច់ ឬក្រួស ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត<br>(កថាខណ្ឌទី១ មាត្រា៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ១ ៥០០ ០០០ ក្នុងមួយថ្ងៃ ឬស្មើនឹង២ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែដែលជីកយកបាន ដោយជ្រើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង |
| ២ | ២ សម្បទានិកដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ អស់សុពលភាព សម្រាប់ការបូមយកខ្សាច់ ដី ល្បាប់ ឬក្រួស តាមផ្លូវទឹក ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត<br>(កថាខណ្ឌទី១ មាត្រា៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ១ ៥០០ ០០០ ក្នុងមួយថ្ងៃ ឬស្មើនឹង២ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែដែលជីកយកបាន ដោយជ្រើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង |
| ៣ | ៣ សម្បទានិកដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ អស់សុពលភាព សម្រាប់អាជីវកម្មរ៉ែមាស ក្រោមទម្រង់ជាការដ្ឋានអណ្តូងរ៉ែបើក ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត<br>(កថាខណ្ឌទី១ មាត្រា៣៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ១ ៥០០ ០០០ ក្នុងមួយថ្ងៃ ឬស្មើនឹង២ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែដែលជីកយកបាន ដោយជ្រើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង |

| លេខរៀងបទល្មើស | បរិយាយប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| ៤ | ៤ សម្បទានិកដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ អស់សុពលភាព សម្រាប់អាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ពាក់កណ្ដាលមានតម្លៃ និងថ្មសំអាង ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត<br>(កថាខណ្ឌទី១ មាត្រា៣៦ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ១ ៥០០ ០០០ ក្នុងមួយថ្ងៃ ឬស្មើនឹង២ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែដែលជីកយកបាន ដោយជ្រើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង |
| ៥ | ៥ សម្បទានិកដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ អស់សុពលភាព សម្រាប់គោលបំណងអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ពាក់កណ្ដាលមានតម្លៃ និងថ្មសំអាងជាលក្ខណៈខ្នាតតូច ក្រោមទម្រង់ជាការដ្ឋានអណ្ដូងរ៉ែក្រោមដី ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត<br>(កថាខណ្ឌទី១ មាត្រា៣៦ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ១ ៥០០ ០០០ ក្នុងមួយថ្ងៃ ឬស្មើនឹង២ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែដែលជីកយកបាន ដោយជ្រើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង |
| ៦ | ៦ សម្បទានិកដែលធ្វើប្រតិបត្តិការជីកយករ៉ែដោយអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ អស់សុពលភាព សម្រាប់អាជីវកម្មរ៉ែមាសជាលក្ខណៈខ្នាតតូចក្រោមទម្រង់ជាការដ្ឋានអណ្ដូងរ៉ែក្រោមដី ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត<br>(កថាខណ្ឌទី១ មាត្រា៣៦ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ) | ១ ៥០០ ០០០ ក្នុងមួយថ្ងៃ ឬស្មើនឹង២ដង នៃតម្លៃប៉ាន់ស្មានលើផលិតផលរ៉ែដែលជីកយកបាន ដោយជ្រើសយកការផាកពិន័យណាមួយដែលមានចំនួនច្រើនជាង |
| ៧ | II- **ការផាកពិន័យក្នុងករណីបង់ប្រាក់យឺតយ៉ាវហួសកាលបរិច្ឆេទតម្រូវឱ្យបង់ប្រាក់** (គិតក្នុងមួយខែ តាមរូបមន្តសមាស) | ២%នៃទឹកប្រាក់ត្រូវបង់ |